ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងឧបករណ៍មាត្រាសាស្ត្រ ផ្ទៃកចំណុះ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

~~-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤~~ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់បង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញ អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញ ប្រកាសលេខ ១៥៤ បល.ប្រក ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០០ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋានមាត្រាសាស្ត្រ

-ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## សម្រេច

**ប្រការ១ :** ឧបករណ៍មាត្រាសាស្ត្រផ្ទៃកចំណុះនៃវត្ថុរាវ ត្រូវបានកំណត់តាមចំណុះជា ១លីត្រ ៥លីត្រ ១០លីត្រ ២០លីត្រ និងចំណុះពហុគុណ-អនុពហុគុណនៃឧបករណ៍មាត្រាសាស្ត្រផ្ទៃកចំណុះនៃវត្ថុរាវដទៃទៀត។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

**ប្រការ៥ :** ,ការធ្វើព្យាសកម្មខ្នាតមាត្រាសាស្ត្រផ្ទៃកចំណុះនៃវត្ថុរាវ ត្រូវអនុវត្តតាមលក្ខខណ្ឌ ដូចតទៅ៖

<u>ក-ការធ្វើព្យាសកម្ម</u>

-សីតុណ្ហភាពជាគោល សំរាប់ធ្វើព្យាសកម្ម ចំពោះឧបករណ៍ខ្នាតមាត្រាសាស្ត្រផ្ទៃកចំណុះនៃវត្ថុរាវ គឺ ២០ អង្សាសែលស៊ុស ។

-ការក្រិតចំណុះ ត្រូវអនុវត្តតាមការចាក់ចូលឬការចាក់ចេញនៃវិធីវាល់ចំណុះ ឬតាមវិធីថ្លឹង ។

-ការកំណត់ចំណុះនៃការព្យាសកម្ម ឧបករណ៍ខ្នាតមាត្រាសាស្ត្រ ផ្ទៃកចំណុះនៃវត្ថុរាវត្រូវប្រើរយៈពេល ៣០ វិនាទី សំរាប់បង្ហូរបង្ហើយចុងក្រោយនៃវត្ថុរាវ ។

<u>ខ-កំរិតលំអៀង</u>

-កំរិតលំអៀងសំរាប់ឧបករណ៍ខ្នាតមាត្រាសាស្ត្រផ្ទៃកចំណុះនៃវត្ថុរាវ មិនអោយលើស ±0,1 % នៃបរិមាណកំណត់ ។ ចំពោះការត្រួតពិនិត្យបំរើការក្នុងសកម្មភាពសេវាកម្ម កំរិតលំអៀងដែលអនុញ្ញាតក្នុងចន្លោះ ±0,5 % នៃបរិមាណកំណត់ ។

**ប្រការ៦ :** អង្គភាពសមត្ថកិច្ចមាត្រាសាស្ត្រ គ្រប់អង្គភាពពាក់ព័ន្ធ គ្រប់សមាសភាពសេដ្ឋកិច្ច ផលិតកម្ម-អាជីវកម្មមានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួន តាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

<u>ចម្លងជូន:</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង-ស្ថាប័នកណ្តាល

-គ្រប់សាលាខេត្ត-ក្រុង

"<u>ដើម្បីជ្រាបជាពត៌មាន</u>"

-ដូចប្រការ៦

"<u>ដើម្បីមុខការនិងអនុវត្ត</u>"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ